# របាយការណ៍

## ការចុះធ្វើផែនទីរណ្តៅសាកសពនៅស្រុកឧិរ៉ាល់ ស្រុកភ្នំស្រួច និងស្រុកខត្តុង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៥-២២ ខែកក្កដា ឆ្នាំ២០០១

១) ស្រុកឧិរ៉ាល់

ថ្ងៃទី១៥-១៧ ខែកក្កដា ឆ្នាំ២០០១

មន្ទីរសន្តិសុខ ៩៩

ព្រឹត្តិការណ៍នយោបាយចាប់ពីដើមឆ្នាំ១៩៧០មក ធ្វើឲ្យមនុស្សភាគច្រើននៅទូទាំងប្រទេសកម្ពុជាពិបាកស្វែងយល់និងមិនងាយពិចារណាដឹងឡើយថាជានយោបាយដែលមានទំនោរទៅខាងណាច្បាស់លាស់ ។ តំបន់ប្រទាញប្រទង់ ឬតំបន់ស្វយត័ជាច្រើនត្រូវបានបង្កើតឡើងនៅតាមតំបន់ដាច់ស្រយាលពីទីប្រជុំជន ។ជីវិតប្រជាជនស្ថិតនៅក្រោមការគៀបសង្កត់ស្ទើរតែរើខ្លួនមិនរួចពីនឹមត្រួតត្រានៃអ្នកក្តោបក្តាប់មូលដ្ឋានទាំងពីរបក្សក្នុងតំបន់ ។ ចលនាឃោសនាអូសទាញគ្រប់ប្រភេទនៃអ្នករំដោះ បានលូកដៃចូលមកកកូរកកាយផ្ទៃក្នុងនៃរបបលន់ណុល ។ ដំណើរការរកស៊ីចិញ្ចឹមជីវិតត្រូវខកខានព្រោះតែសភាពការណ៍នយោបាយបន្ទំ ។ ការធ្វើដំណើរចាកចោលពីផ្ទះសម្បែង ជាគោលដៅតែមួយគត់ដើម្បីស្វែងរកទីជ្រកកោនដែលមានសេចក្តីសុខ និងគេចពីការបាញ់ផ្លោងដាក់គ្នាស្ទើរលោះថ្ងៃ ។ ព្រឹត្តិការណ៍ប្លែកៗតែងកើតមានឡើងជាលំដាប់ទាំងការជ្រើសរើសឲ្យចូលទ័ពពីរបបលន់ណុល, ការរត់ចូលព្រៃតាមការឃោសនាពីខ្មែររំដោះ, ការរត់គេចខ្លួន បូករួមទាំងការបង្កើតមន្ទីរសន្តិសុខនានានៅតាមតំបន់ស្វយត័របស់ខ្មែររំដោះនាសម័យសង្គ្រាមក្នុងតំបន់ប្រទាញប្រទង់ ។
ប្រជាកសិករនៅ តាមតំបន់ដាច់ស្រយាលទាំងនោះ វិលមុខនឹងសភាពការណ៍បែបនេះ ។ ទឹកដី ព្រៃភ្នំ រួមនឹងជីវិតប្រជាជន
បានក្លាយជាឧបករណ៍ទាក់ទាញក្នុងការប្រឈមមុខដាក់គ្នារវាងបក្សពួកខាងលន់ណុលនិងខាងខ្មែររំដោះ ។ មន្ទីរសន្តិសុខចំនួនបីត្រូវបានបង្កើតឡើងតែក្នុងចន្លោះឆ្នាំ១៩៧០និង១៩៧៥ ក្នុងទឹកដីឃុំតាសាល ស្រុកភ្នំស្រួច ដែលបច្ចុប្បន្នស្ថិតនៅក្នុងទឹកដីឃុំតាសាល និងឃុំរស្មីសាមគ្គី ស្រុកឧិរ៉ាល់វិញ ។ ការផ្តល់ឈ្មោះឲ្យមន្ទីរសន្តិសុខជាលេខ គឺជាប្រការមួយដែលងាយស្រួលចាំសម្រាប់ពួកខ្មែររំដោះ ប៉ុន្តែគ្មានប្រភពណាមួយអះអាងថា ការតាងដោយលេខនោះជំនួសឲ្យអ្វី ឬតំណាងអ្វីទេ ។ មន្ទីរសន្តិសុខដែលបាន បង្កើតដំបូងត្រូវដាក់ឈ្មោះថា «មន្ទីរ៧៧» ទីពីរឈ្មោះថា «មន្ទីរ៨៨» និងទីបីមានឈ្មោះថា «មន្ទីរ៩៩» ។ មន្ទីរទាំងបីនេះមានឃុំឃាំងប្រភេទមនុស្សខុសៗគ្នា ហើយការគ្រប់គ្រងក៏មានសភាពខុសៗគ្នាដែរ ។ មន្ទីរ៧៧ បានបង្កើតមុនគេបង្អស់នៅឆ្នាំ១៩៧០ដោយខ្មែររំដោះ ។ មនុស្សដែលបានមកជាប់នៅមន្ទីរនេះគឺជាឈ្លើយសឹកទាហានលន់ណុល ។

មន្ទីរ៧៧ មានឈ្មោះហៅមួយទៀតថា មន្ទីរអប់រំកែប្រែ ។ ទាហានឈ្លើយសឹកទាំងអស់ មិនត្រូវបានសម្លាប់ទេ គឺបានត្រឹមអប់រំកែប្រែនិងបំពាក់គោលមាគ៌ានយោបាយផ្សេងៗប៉ុណ្ណោះ ហើយបន្ទាប់ត្រូវដោះលែងឲ្យមករស់នៅតំបន់រំដោះរហូត ។ ចំណែកមន្ទីរ៨៨វិញត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧២ដោយខ្មែររំដោះដូចគ្នាបន្ទាប់ពីបានរំលាយមន្ទីរ៧៧ចោល ។ មន្ទីរនេះ មានឃុំឃាំងមនុស្សជាប្រភេទអ្នករកស៊ីឆ្លងទៅឆ្លងមកពីតំបន់រំដោះទៅតំបន់ដែលគ្រប់គ្រងដោយរបបលន់ណុល ។ ឈ្មួញរកស៊ីទាំងនោះ បន្ទាប់ពីចាប់បានហើយ ត្រូវទទួលការអប់រំកែប្រែនិងបណ្តុះមនោគមវិជ្ជាផ្សេងៗដូចនៅមន្ទីរ៧៧ដែរ ប៉ុន្តែការគ្រប់គ្រងលើកនេះមានសភាពខុសប្លែកបន្តិចបន្តួចប៉ុណ្ណោះត្រង់ថា មានការធ្វើពលកម្មច្រើន មានការបែងចែកប្រភេទកំហុសធ្ងន់ និងស្រាល ។ ឯការសម្លាប់មិនទាន់កើតមានទេ ។ គណៈគ្រប់គ្រងនៅមន្ទីរ៨៨នេះ តាមសម្តីរបស់លោកជំទប់លេខមួយឃុំរស្មីសាមគ្គីឈ្មោះ ហង់ ជិន ថាមានឈ្មោះញ៉ែម ស៊ុន[1] ជាអ្នកបង្កើតមន្ទីរ៨៨នេះឡើង ហើយមានឈ្មោះ **ឆាត់** ជាប្រធានមន្ទីរ៨៨ និងមានឈ្លបជាច្រើននាក់ទៀតជាកងសន្តិសុខ ។ ចំពោះទោសដែលស្រាល ត្រូវដោះលែងឲ្យមករស់នៅតំបន់រំដោះដោយមិនអនុញ្ញាតិឲ្យទៅលេងស្រុកឡើយ ។ ចំណែកទោសធ្ងន់វិញ មិនបានដោះលែងទេ គឺទុកនៅក្នុងមន្ទីរនេះរហូតទាល់តែមានមន្ទីរថ្មីមួយទៀត ទើបបញ្ជូនមនុស្សទាំងនោះទៅដាក់បន្តនៅមន្ទីរថ្មីដែលទើបបង្កើតក្រោយ ។ នៅដើមឆ្នាំ១៩៧៣ មន្ទីរ៩៩ បានបង្កើតឡើង ។ មន្ទីរ៨៨ ត្រូវបានរុះរើ និងចូលខ្លួនជាសមាជិកក្នុងមន្ទីរ៩៩ ។ អ្នកទោសប្រភេទធ្ងន់ទាំងអស់ត្រូវបញ្ជូនទៅកាន់មន្ទីរ៩៩ ។

ខាងក្រោមនេះជាហេតុការណ៍ដែលបានកើតឡើងនៅមន្ទីរ៩៩ ដែលខ្ញុំបានដឹងក្រោយពីការសម្ភាសន៍ជាមួយមនុស្សបីបួននាក់នៅឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ហើយក្នុងនោះមានម្នាក់ជាអតីតអ្នកទោសនៅមន្ទីរ៩៩ និងម្នាក់ទៀតជាអ្នកបានចូលទៅក្នុងគុក៩៩ដើម្បីមើលគំរូខ្នោះដាក់អ្នកទោស ព្រោះគាត់ជាជាងធ្វើខ្នោះឲ្យមន្ទីរ៩៩នៅឆ្នាំ១៩៧៣ ។

មន្ទីរនេះ មិនបានចុចយកចំណុចខ្សែស្របនិងរយៈទទឹងនៃភូមិសាស្ត្របានឡើយ ព្រោះក្រុមស្រាវជ្រាវ យើងមិនបានចូលដល់បានដោយសារបញ្ហាផ្លូវពិបាក ឆ្ងងស៊ើង ជាពិសេសគ្មានទូកប្តូរសម្រាប់ចម្លងក្រុម យើងទៅបានទេ សូម្បីតែម្ចាស់ស្រុកនៅទីនោះ ក៏ថាមិនអាចទៅបានដែរ ។ ទោះជាយ៉ាងនេះក៏ដោយ ព័ត៌មាន ដែលទាក់ទងរឿងរ៉ាវកើតឡើងនៅមន្ទីរ៩៩

[1] តាមកិច្ចសម្ភាសន៍របស់ខ្ញុំ(ដេង ពង្សរ៉ាស៊ី) ផាត កុសល និង សាន់ កល្យាន ជាមួយលោកយាយ គល់ ម៉ីអាយុ៦៥ឆ្នាំ កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០០នៅស្រុកត្រាំកក់ ខេត្តតាកែវថា ឈ្មោះ ញ៉ែម ស៊ុននេះជាពួកម៉ាកជិតស្និទ្ធជាមួយ តាម៉ុក ឬតា១៥ កាលពីសម័យតស៊ូជាមួយគ្នា ។

ត្រូវបានរាយការណ៍យ៉ាងលម្អិតពីសំណាក់ប្រជាជនមួយចំនួនក្នុង ភូមិរស្មី ឃុំរស្មីសាមគ្គី ប្រាប់ដល់ក្រុមស្រាវជ្រាវយើង ហើយត្រូវបានលើកយកមកសរសេរក្នុងបន្ទាត់ខាង ក្រោមនេះ៖

មន្ទីរ៩៩ ត្រូវបានបង្កើតឡើងក្នុងគោលបំណងឃុំឃាំងនិងធ្វើទារុណកម្មមនុស្សដែលពួកខ្មែរក្រហមគិតថាមានកំហុស ឬក្បត់នឹងអង្គការ ។ មនុស្សជាច្រើននាក់បានមកជាប់នៅមន្ទីរនេះ ហើយត្រូវបានសម្លាប់ចោលយ៉ាងព្រៃផ្សៃបំផុតបន្ទាប់ពីសួរចម្លើយរួចនៅប្រហែលជាពីរគីឡូម៉ែត្រប៉ុណ្ណោះពីមន្ទីរ ។ មន្ទីរ៩៩មានទីតាំងស្ថិតនៅនៅក្នុងព្រៃរហោឋានមួយក្នុងទឹកដីឃុំតាសាល ស្រុកភ្នំស្រួច ដែលមានចម្ងាយឆ្ងាយដាច់ស្រយ៉ាល ពីភូមិរបស់ប្រជាជន ។ មន្ទីរនេះត្រូវបានគ្រប់គ្រងដោយខ្លួនឯងមិនពឹងកម្លាំងខាងក្រៅឡើយ ។ រាល់សេចក្តី ត្រូវការក្នុងមន្ទីរគឺត្រូវផលិតខ្លួនឯងដោយផ្អែកលើកម្លាំងអ្នកទោស ទាំងការបង្កបង្កើនផល ការនេសាទ និងការផលិតឧបករណ៍ប្រើប្រាស់ផ្សេងៗទៀត ។ ដំបូងឡើយមានឈ្មោះ **ខាន់** ជាគណៈគ្រប់គ្រងក្នុងមន្ទីរទាំងមូល ហើយមានឈ្មោះ **ឆែ** ជាប្រធានឈ្លប ។ ក្រោយមកមានឈ្មោះ **គុល** ជាអ្នកមកជំនួសវិញ ។ មិន បានប៉ុន្មានផង មានដែនការផ្លាស់ប្តូរ**តាគល់**ចេញទៀត ហើយយកមកដាក់ជំនួសដោយ**តាណាម** រហូតដល់បែកមន្ទីរនេះនៅឆ្នាំ១៩៧៧ ។ **ខាន់ គុល និង ណាម** បានគ្រប់គ្រងទៅលើអ្នកទោសជាច្រើនពាន់នាក់ដែលបានបញ្ជូនមកពីខេត្តតាកែវ កំពត ព្រៃវែង ស្រែអំបិល កងទ័ព(កងទ័ព៨២០ប្រចាំតំបន់៣២ កងទ័ព១៣៧) ស្រុកប្រាំបីមុំ ស្រុកថ្ពង ស្រុកឧត្តុង្គ និងកន្លែងផ្សេងៗទៀតក្នុងខេត្តកំពង់ស្ពឺ ជាពិសេសស្រុកភ្នំស្រួច ។ ឯ**ឆែ** វិញជាមេពិជឃាតយ៉ាងសាហាវមួយ ដែលគ្រាន់តែបញ្ជាកូនឈ្លបឲ្យយកអ្នកទោសទៅសម្លាប់ចោល ប៉ុណ្ណោះ ។ មានកងឈ្លបជាច្រើននាក់នៅក្នុងមន្ទីរ៩៩ ដែលឈ្លបទាំងនោះមានឈ្មោះហៅថា «**ឈ្លបសម្ងាត់ប្រចាំ៩៩**» ។ អាយុរបស់ពួកគេមិនលើសពី៣០ឆ្នាំឡើយ ។ ចំណែកឈ្លបនៅតាមមូលដ្ឋាន តាមសហករណ៍មិនអនុញ្ញាតិឲ្យចូលក្នុងមន្ទីរទេ ។ ប្រជាជនជាច្រើនសុទ្ធតែត្រូវបានចោទទាំងគ្មានការពិតថាជាខ្មាំងសត្រូវរបស់អង្គការ ។ អំណាចនៃការកាន់កាប់នៅមន្ទីរ៩៩ កាន់តែជះឥទ្ធិពលធំឡើងៗជាលំដាប់ខាងការសម្លាប់និងធ្វើទារុណកម្មលើប្រជាជន ។ ក្រោយព្រឹត្តិការណ៍មហាជ័យជំនះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ មនុស្សជាច្រើនបាន បញ្ជូនមកកាន់មន្ទីរ៩៩ ក្រោមការគ្រប់គ្រងរបស់ **តាគុល** និង **តាណាម** ។ លោកពូ ហង្ស ជិនអាយុ៥៥ឆ្នាំ ជាជំទប់លេខមួយឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ បានប្រាប់ថា «ថ្ងៃណាក៏នាំមនុស្សចូលដែរ» ។ ប្រជាជនដែលគ្មានកំហុស ត្រូវបានហាមឃាត់មិនឲ្យទៅជិតមន្ទីរឡើយ ព្រោះជាការខុសឆ្គងមួយសម្រាប់ អង្គការ ។ ប៉ុន្តែអាចដើរបានតែឈ្លបដែលនាំមនុស្សចូលទៅប៉ុណ្ណោះ ។

ចំណែកទិដ្ឋភាពខាងក្នុងមន្ទីរ៩៩វិញបានឆ្លុះបញ្ចាំងឲ្យឃើញយ៉ាងច្បាស់ពីចរិកកាចសាហាវ ដួរជាតិនៃពួកកងឈ្លបក្រោមបញ្ជាផ្ដាច់ការនៃមេធំៗក្នុងមន្ទីរ ។ ទិដ្ឋភាពទាំងនេះ ត្រូវបានរៀបរាប់យ៉ាងក្បោះក្បាយដោយលោកតា យ៉ែម យឹម បន្ទាប់ពីគាត់ត្រូវបាននាំចូលទៅក្នុងមន្ទីរ៩៩ នៅឆ្នាំ១៩៧៣ថា មន្ទីរ៩៩មានបរិវេណធំហើយស្ងាត់ ។ មានបែងចែកប្រភេទអ្នកទោសធ្ងន់និងស្រាល ។ មានកន្លែងធ្វើការសម្រាប់ពួកមេដឹកនាំ ។ មានកន្លែងធ្វើទារុណកម្ម និងកន្លែងសួរចម្លើយនៅប៉ែកខាងជើងមន្ទីរ ។ មានខ្សែពួរសម្រាប់ចងជើងព្យួរអ្នកទោសចូលក្នុងរណ្ដៅ ។ មានរណ្ដៅធំៗ ដែលមានភ្លើងកំពុងឆេះយ៉ាងគគុលនៅខាងក្នុង និងនៅមានឧបករណ៍ផ្សេងៗ ... ។ លោកតាបាននិយាយប្រាប់ថា «ខ្ញុំឃើញមានខ្ទោះពីរខ្សែក្នុងមួយបន្ទប់ ហើយខ្ទោះនោះ ជាខ្ទោះឈើដែលមានចោះប្រហោងល្មមនឹងដាក់កជើងបាន និងមានរនុកគ្របពីលើព្រមទាំងវ៉ៃស្នៀតយ៉ាង តឹង» ។ លោកតាបន្តថា «ខ្ញុំបានឃើញអ្នកទោសគឺជើងម្ខាងនៅក្នុងខ្ទោះ និងជើងម្ខាងទៀតនៅក្រៅខ្ទោះ ហើយកំពុងធ្វើការយ៉ាងមមីះដូចជា ធ្វើអំបោស គៀបផាងត្នោត វិញខ្សែ ធ្វើកន្ត្រក...» ។ ក្នុងមួយបន្ទប់មានអ្នកទោសពីរខ្សែ គឺមួយខ្សែក្បាលទៅលិច និងមួយខ្សែទៀតក្បាលទៅកើត ។ លោកពូ ហង់ ជិន បានប្រាប់ថាចំពោះអ្នកទោសធ្ងន់ គឺដាក់ឲ្យនៅក្នុងរណ្ដៅដែលមានជម្រៅ៣ម៉ែត្រ រហូតទាល់តែមានការសួរចម្លើយកើតឡើង ។ លោកពូបានរៀបរាប់យ៉ាងលម្អិតថា អ្នកទោសដែលអង្គការចាត់ទុកថាជាប្រភេទធ្ងន់ពេលដែលចាប់យកមកគឺ ពួកកងឈ្លបសម្ងាត់បានដាក់បង្អោងឲ្យចុះទៅក្នុងរណ្ដៅ ហើយលើកបង្អោងមកវិញ ។ នៅពីលើមាត់រណ្ដៅមានធ្វើជារោងដែលមានសំយ៉ាបដំបូងធ្លាក់ដល់ដីគ្របពីលើ ។ រណ្ដៅទាំងអស់មានចំនួនបួន ហើយរណ្ដៅនីមួយៗ អាចដាក់អ្នកទោសបានច្រើន ។ ពេលហូបបាយ និងពេលធ្វើការម្ដងៗ អ្នកទោសទាំងនោះបានត្រូវដាក់បង្អោងឲ្យឡើងមក ហើយដាក់បង្អោងឲ្យចុះទៅក្រោមវិញ បន្ទាប់ពីធ្វើការ និងហូបបាយរួច ។ ទោះជាសម្រាកបន្តិចបន្តួចក្រោយពេលធ្វើការ ក៏តម្រូវឲ្យចុះទៅក្នុងរណ្ដៅដែរ ។ អ្នកទោសម្នាក់ៗសុទ្ធតែត្រូវឆ្លងកាត់ការសួរចម្លើយជាមុនសិន ទើបត្រូវសម្រេចយកទៅសម្លាប់ចោល ។ មានវិធីច្រើនណាស់ក្នុងការធ្វើទារុណកម្មដើម្បីយកចម្លើយដូចជាវាយធ្វើបាប ចងព្យួរជើងឡើងលើជ្រមុជក្បាលក្នុងទឹកនិងក្នុងភ្លើង.... ។ ចម្លើយដែលពួកខ្មែរក្រហមចង់បានបំផុតនោះគឺការឆ្លើយដាក់ទៅលើឈ្មោះអ្នកផ្សេងទៀតដែលធ្លាប់ពាក់ព័ន្ធ នឹងសកម្មភាពក្បត់របស់ខ្លួន ។ ទោះជាមានការឆ្លើយត្រង់ ឬមិនត្រង់ក៏ដោយ ក៏វាសនាមានតែមួយទេគឺ «**ស្លាប់**» ។ រាល់ការសួរចម្លើយសុទ្ធតែបានចម្លើយយ៉ាងសមស្របមួយដែលពួកកងឈ្លបខ្មែរក្រហមគិតថា ខ្លួនពូកែខាងការសួរចម្លើយ ។ ឈ្មោះមនុស្សដែលត្រូវបានពួកអ្នកទោសឆ្លើយដាក់សុទ្ធតែត្រូវស្វែងរកចាប់ខ្លួន ជាបន្ទាន់ និងបញ្ជូនមកកាន់មន្ទីរ៩៩ទាំងអស់ ។ ជីវិតនៃមនុស្សទាំងនោះ នឹងត្រូវបញ្ចប់តែក្នុងរយៈពេល ខ្លីខាងមុខ ។

ការធ្វើរបៀបនេះ នៅតែមានជាហូរហែរ ហើយមនុស្សក៏នៅតែមានចាប់មកកាន់មន្ទីរជារៀង រាល់ថ្ងៃដែរ ។ ឯអ្នកទោសចាស់ៗ ក៏ត្រូវបាត់ខ្លួនជាបណ្តើរៗរហូតដែរ ។

នៅខែ៧ឆ្នាំ១៩៧៧ សង្គ្រាមផ្ទៃក្នុងមួយបានផ្ទុះឡើងនៅមន្ទីរ៩៩ ។ រឿងរ៉ាវដែលបណ្តាលឲ្យមានជាបញ្ហាឡើងគឺ ដោយសារតែមានការផ្លាស់ប្តូរប្រធានឈ្លបឈ្មោះ **ឆែ** ឲ្យទៅធ្វើការនៅព្រៃសរ ហើយប្តូរមនុស្សផ្សេងមកវិញ ព្រោះតាំងពីបង្កើតមន្ទីរ៩៩មក ឈ្មោះ **ឆែ** មិនដែលផ្លាស់ប្តូរទៅណាទេ ទើបតែពេលនេះប៉ុណ្ណោះដែលធ្វើឲ្យ**ឆែ**រង្កៀសចិត្ត ហើយសង្ស័យថា ខ្លួនពិតជាត្រូវជាប់គុកនៅព្រៃសរ ដោយមូលហេតុថ្នាក់លើដឹងថា ខ្លួនបានប្រព្រឹត្តខុសសីលធម៌ជាមួយនារីកងទ័ព៣២០ជាច្រើននាក់ដែលបានជាប់នៅក្នុងមន្ទីរ ។ ភាពវឹកវរបានចាប់ផ្តើមឡើង អាវុធក៏បានផ្ទុះស្របពេលគ្នាដែរ ។ លោកពូហេង លឹម ហ៊ី ដែលជាអ្នកដឹងហេតុការណ៍នេះ បានរៀបរាប់ពីព្រឹត្តិការណ៍នាថ្ងៃផ្ទុះសង្គ្រាមផ្ទៃក្នុងនៅមន្ទីរ៩៩ថា "ថ្ងៃមួយនោះខ្ញុំឃើញ**តាគល់**ជិះម៉ូតូចូលមកកាន់មន្ទីរ៩៩ និយាយជាមួយ **តាឆែ** ។ បន្ទាប់មក **តាឆែ** ក៏មានការខឹងប្រឡោតយ៉ាងខ្លាំងនូវសម្តីរបស់ **តាគល់** ដែលនិយាយថា "ផ្លាស់ទៅនៅព្រៃសរ" ។ រំពេជនោះស្រាប់តែមានឈ្មោះ **វើត** ដែលជាប្អូនរបស់**ឆែ** បានបាញ់សន្ធាប់យ៉ាងខ្លាំងទៅលើហ្វូងមនុស្ស ដែលក្នុងនោះ **វើត** បានសម្លាប់អ្នកទោសស្លាប់អស់៥-៦នាក់ រួមនឹង **តាគល់** ម្នាក់ផងនៅនឹងកន្លែងក្នុងមន្ទីរ៩៩ ។ លោកពូបានបន្តថា "**ឆែ** ជាមនុស្សដែលដឹងខ្លួនឯងថា បានខូចសីលធម៌ជាមួយនារីអ្នកទោសជាច្រើននាក់ណាស់ ហើយខ្លាចថ្នាក់លើសម្លាប់ខ្លួនព្រោះរឿងនេះ គេ(**ឆែ**)ក៏វ៉ៃប្រហារមុនទៅ" ។ ក្រោយព្រឹត្តិការណ៍ មានមនុស្សដែលជាប់ពាក់ពន្ធ័មួយចំនួនទៀត ត្រូវតាមសម្លាប់ និងមួយចំនួនទៀតត្រូវរកវិធីសម្លាប់ខ្លួនឯង ដើម្បីជៀសវាងការតាមសម្លាប់ ។ **សែ** ដែលជាអនុប្រធានរបស់ **ឆែ** បានខ្វេះបំពង់កដោយកាំបិតបំណាងសម្លាប់ខ្លួនឯង ព្រោះគិតថាប្រសើរជាងការតាមចាប់ខ្លួនយកទៅព្រៃសរពីថ្នាក់លើ ។ ចំណែក **តាណម** បានបាញ់សម្លាប់ខ្លួនឯង ព្រោះគិតថាប្រសើរជាងទុកជីវិតឲ្យ**ឆែ** ជាអ្នកសម្លាប់ ។ រឿងរ៉ាវដែលបានកើតឡើងត្រូវបានបញ្ចប់ មន្ទីរ៩៩ត្រូវរំលាយចោល បន្ទាប់ពីមានការប្រមូលអ្នកទោសជាច្រើនសន្ធឹកសន្ធាប់យកទៅសម្លាប់ចោលនៅកន្លែងធំៗពីរគឺ **ទួលដូនពេញ** និង **ទួលមាំុង** ។ ទួលទាំងពីរនេះ ស្ថិតនៅចន្លោះជ្រលងភ្នំបីគឺភ្នំរាជកុង ភ្នំតាប៉ោល និងភ្នំតូច ។ ចំណែកអ្នកទោសមួយចំនួនត្រូវបាននាំខ្លួនបន្តទៅកាន់"**មន្ទីររបស់តាឌុច**" ដែលមានទីតាំងស្ថិតនៅឯភ្នំពិស ខាងលិចឃុំអមលាំង ស្រុកថ្ពង និងខាងត្បូងឃុំត្រពាំងជោរ ។ តាមការអះអាងពីលោកពូលឹម ហ៊ី ថា **មន្ទីរតាឌុច** ជាមន្ទីរដែលបានធ្វើទារុណកម្ម និងសម្លាប់ខ្លាំងដូចនៅមន្ទីរ៩៩ដែរ ។

ព្រឹត្តិការណ៍ដ៏ញាក់សាច់ក្នុងមន្ទីរ៩៩ បានផុតរលត់ទៅជាមួយនឹងជីវិតមនុស្សស្លូតត្រង់រាប់ពាន់ រាប់ម៉ឺននាក់តែក្នុងរយៈពេលជិត៤ឆ្នាំនៃការកាន់កាប់របស់បក្សពួកខ្មែរក្រហម ។ ទង្វើរដ៏សាហាវយង់ឃ្នងរបស់អ្នក

កាន់អំណាចនៅក្នុងមន្ទីរបានធ្វើឲ្យក្រុមគ្រួសារនៃប្រជាជនទាំងឡាយបែកបាក់គ្នារហូតដល់សព្វថ្ងៃ និងធ្វើឲ្យពួកគាត់មានការឈឺចាប់អស់មួយជីវិត ។

**ទីតាំងសម្លាប់ទួលដូនពេញ** **លេខកូដភូមិសាស្រ្តៈ ០៥០៨០១**

រណ្តៅសាកសពនៅទួលដូនពេញមានបីកន្លែងដែលត្រូវយកមនុស្សពីមន្ទីរ៩៩មកសម្លាប់ ។ រណ្តៅទាំងនោះមាន៧ម៉ែត្រទទឹង ៦ម៉ែត្របណ្តោយ និងជំរៅ២ម៉ែត្រ ។ លោកអ៊ឹ ហង់ ជិននិយាយថា គាត់ជាអ្នកធ្វើរណ្តៅនេះដោយខ្លួនឯងកាលពីឆ្នាំ១៩៦៦ ពេលដែលលោកអ៊ឹបំរើការងារឲ្យបារាំង ។ រណ្តៅដែលលោកអ៊ឹបាន ជីកជាប្រភេទរណ្តៅរ៉ែ ដែលស្ថិតនៅចន្លោះខាងកើតភ្នំតាប៉ោល, ភ្នំរាជកុង និងខាងលិចភ្នំតូច ។ រណ្តៅរ៉ែ បានក្លាយជារណ្តៅសម្រាប់កប់សាកសពតាំងពីឆ្នាំ១៩៧៣មកពេលដែលបង្កើតមន្ទីរ៩៩ភ្លាម ។ សាកសព ដែលបានស្លាប់ទាំងបីរណ្តៅ លោកអ៊ឹបានប៉ាន់ស្មានថាមានប្រហែលជា៨០០០-៩០០០នាក់ ។

ទីតាំងនេះបានកត់ត្រាទុកតាមប្រពន្ធ័កំណត់តាមផ្កាយរណបនូវចំណុចខ្សែស្របលេខ 9ណដ ១១° ៣៥' ៣៧"៨០ និងរយៈទទឹង9ៃដ ១០៤° ០៥' ៤៣"០០ ។

**ទីតាំងសម្លាប់ទួលមាំុង**

ទីតាំងនេះមិនបានចុចយកនូវចំណុចខ្សែស្របតាមរយៈផ្កាយរណបទេ ព្រោះស្ថិតនៅក្នុងព្រៃភ្នំជ្រៅៗដែលមិនអាចទៅបាន ។ តាមការអះអាងពីលោកជំទប់លេខ១ឃុំរស្មីសាមគ្គីថា អាចមានសត្វសាហាវៗដូចជាខ្លាជាដើម ម្យ៉ាងទៀតត្រូវចំណាយពេលដើរក្នុងព្រៃរយៈពេលយូរ ។ ទីតាំងនេះមានការសម្លាប់មនុស្សយ៉ាងច្រើនដែលមិនអាចរាប់បានដែរ ។ តាមសម្តីរបស់លោកអ៊ឹម អ៊ុត អាយុ៦២ឆ្នាំថា នៅលើទួលមាំុង មានសាកសពច្រើនណាស់នៅលើពាសពេញដី ។ គាត់ក៏បានបញ្ជាក់ដែរថា កាលពីដើមប្រវត្តិទួលមាំងនេះ មានឈ្មោះដើមថា ទួលដូនអែប ។ លុះដល់ពេលរបបដែលគ្រប់គ្រងដោយប៉ុលពត ទួលនេះបានប្រែក្លាយឈ្មោះទៅជា ទួលមាំុង ហើយប្រជាជននៅតែបន្តហៅទួលមាំុងៗរហូតដល់សព្វថ្ងៃ ។ លោកអ៊ឹបានពន្យល់ពីមូលហេតុនេះថា "ព្រោះកាលណាគេ(ខ្មែរក្រហម) យកមនុស្សមកសម្លាប់នៅលើទួលនេះ គឺគេវ៉ៃ និងបាញ់មាំុងៗគ្មានប្រណី" ។ គាត់បានបន្តថា ការសម្លាប់មនុស្សនៅទួលមាំុងនេះ ជាប្រភេទអ្នកទោសដែលយកមកពីមន្ទីរ៩៩ បន្ទាប់ពីការសម្លាប់នៅទួលដូនពេញ ។ ទីតាំងសម្លាប់នេះស្ថិតនៅខាងជើងភ្នំតូច ហើយនៅបរិវេណជុំវិញទួលមាំុង គឺគ្មានប្រជាជនណាម្នាក់ដែលហ៊ានដើរទៅជិតទេ កាលពីជំនាន់ប៉ុលពត ព្រោះខ្លាចពួកកងឈ្លបចាប់យកទៅសម្លាប់ដូចអ្នកទោស ។ សាកសពត្រូវបានស្ថិតនៅហាលវាល និងគ្មានរណ្តៅសម្រាប់កប់ ។ លោកអ៊ឹម អ៊ុតបានប្រាប់ទៀតថា "ខ្ញុំបានទៅឃើញម្តងដែរ ម៉ាទួលហ្នឹងគឺមានសាកសពស្លាប់រដូករណែល ដូចជាគេក្រាលកន្ទេលឲ្យសម្រានពេលហូបការអញ្ចឹង" ។ ចំពោះការប៉ាន់ស្មានចំនួនសាកសពវិញ ពុំមានអ្នកណាម្នាក់

ដែលយើងបានជួប ហ៊ានធ្វើការសន្និដ្ឋានឡើយ បានត្រឹមតែថា«ច្រើនណាស់ មិនអាចរាប់បានឡើយ»។ ក្រោយសម័យប៉ុលពតទីតាំងនេះ បានបន្សល់ទុកនូវសំណល់ខោអាវផុយៗដែលគ្របដណ្តប់ពីខាងក្រៅឆ្អឹងយ៉ាងច្រើនក្រាលដី។ រហូតមកដល់បច្ចុប្បន្ន ឆ្អឹងនិងខោអាវទាំងនោះ ត្រូវបាត់បង់អស់ដោយការបំផ្លាញពីសត្វព្រៃនានា ក៏ដូចជាការមិនយកចិត្តទុកដាក់ចំពោះការថែរក្សាទុកពីសំណាក់ប្រជាជនដែលនៅសេសសល់ពីការស្លាប់។

៧) ស្រុកភ្នំស្រួច

ថ្ងៃទី១៨-២០ ខែកក្កដា ឆ្នាំ២០០១

**ទីតាំងគុកកប់ផ្អែ** លេខកូដភូមិសាស្ត្រ០៥០៦០៧

មានមន្ទីរសន្តិសុខមួយកន្លែង ស្ថិតនៅក្នុងទឹកដីភូមិស្រែត្រពាំង ឃុំព្រៃក្មេង។ មន្ទីរនេះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៨ ដោយខ្មែររំដោះ ដែលមានឈ្មោះ **សាត់** ជាប្រធាន។ នៅឆ្នាំ១៩៧៣ មន្ទីរនេះត្រូវរំលាយ បន្ទាប់ពីមានការផ្លាស់ប្តូរឲ្យទៅជាកន្លែងដាក់ប្រជាជនដែលជា«ក្រុមប្រវះដៃ»ទៅវិញ។ លោកអ៊ំសាយ អ៊ីម អាយុ៦៥ឆ្នាំ រស់នៅភូមិស្រែត្រពាំង ឃុំព្រៃក្មេង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដែលជាអ្នកបានឃើញហេតុការណ៍កាលពីជំនាន់នោះបានរៀបរាប់ប្រាប់ថា «កាលពីចុងឆ្នាំ១៩៦៨ និងដើមឆ្នាំ១៩៧០ ខ្ញុំធ្លាប់ដើរឆ្លងកាត់តាមមន្ទីរគុកនេះ ហើយខ្ញុំក៏បានឃើញមានអ្នកជាប់គុកនៅពេញតែមន្ទីរដែលសុទ្ធតែជើងជាប់ ខ្នោះឈើវែងៗ»។ តាមការអះអាងពីលោកអ៊ំថា បានឃើញអ្នកទោសប្រហែលជាខ្ទង់២០នាក់ប៉ុណ្ណោះដែល ជាប់ខ្នោះនៅក្នុងរោងវែងមួយក្នុងចំណោមរោងពីរនៃមន្ទីរកប់ផ្អែ។ អ្នកដែលចាប់មកដាក់នៅមន្ទីរកប់ផ្អែគឺចាប់មកពីភូមិព្រៃក្មេង និងចាប់អ្នកដែលជាប់និន្នាការជាមេឃុំចាស់ជំនាន់មុនៗ។ គុកត្រូវបានសាងសង់ជារោងវែងៗ ដែលមានបណ្តោយប្រហែល១០ម៉ែត្រ និងទទឹងប្រហែល៥ម៉ែត្រ។ អ្នកទោសមិនបានចេញទៅធ្វើការនៅខាងក្រៅទេ គឺនៅជាប់ខ្នោះរហូត។ អ្នកទោសប្រភេទស្រាលមួយចំនួន ត្រូវបានដោះលែងប្រសិនបើពួកគេ(ខ្មែររំដោះ)ពិនិត្យទៅឃើញថាពុំមានបញ្ហាអីធំដុំទេនោះ។ ប៉ុន្តែប្រសិនបើទោសធ្ងន់វិញគឺត្រូវ បាននាំយកទៅសម្លាប់ចោល។ ការសម្លាប់អ្នកទោសចោល ប្រព្រឹត្តទៅនៅក្បែរជើងភ្នំភ្លារគង់ដែលមាន ចម្ងាយប្រហែលជា៥០០ម៉ែត្រពីមន្ទីរកប់ផ្អែប៉ែកខាងត្បូង។ ទីតាំងនេះបានកត់ត្រាទុកតាមប្រពន្ធ័កំណត់ តាមផ្កាយរណបនូវចំណុចខ្សែស្របលេខ ឧណថ ១១° ១៧' ៣៥"១៦ និងរយៈទទឹងឧជែ ១០៤° ២៧' ២៦"៧៥។

**ទីតាំងសម្លាប់ព្រៃទួលដា** លេខកូដភូមិសាស្ត្រៈ ០៥០៦០៨

ទួលដា ជាទីតាំងសម្លាប់មួយស្ថិតនៅក្នុងភូមិព្រៃស្រោង ឃុំអូរ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ នៅវេលាម៉ោង១១នឹង៣០នាទី ក្រុមស្រាវជ្រាវយើងបានទៅដល់ទីតាំង ហើយបានចុចយកនូវចំណុចខ្សែស្រប លេខ ១ណជ ១១° ១៩' ១៨០២ និងរយៈទទឹង១ជៃ ១០៤° ១៩' ៣៨៦១ តាមរយៈម៉ាស៊ីនកត់ត្រាអក្សតាមផ្កាយរណប ។ ទៅដល់ទីនោះ នៅស្របតាមផ្លូវចូលទៅកាន់វត្តដំណាក់ត្រាចប្រហែល២គីឡូកន្លះ យើងសង្កេតឃើញ មានព្រៃរបោះជាច្រើនហិកតាដុះនៅលើដីក្រហម និងមានសភាពក្រហេងក្រហូង ។ តាមការបកស្រាយពីលោក លឹម ឡុច អាយុ៦៣ឆ្នាំ រស់នៅភូមិព្រៃស្រោង ឃុំអូរ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ថា «នេះជាទួលដា ដែលជាកន្លែងសម្លាប់មនុស្សកាលជំនាន់ខ្មែរក្រហម» ។ លោកអ៊ំបានបន្តថា «ខ្ញុំដើរមកឃើញគេ(ខ្មែរក្រហម)
យកទាហានពីដោះកញ្ជរប្រហែលជាខ្ទង់ជិត១០០នាក់មកសម្លាប់នៅទីនេះនៅឆ្នាំ១៩៧៥ ពេលរំដោះហើយ ភ្លាមៗ» ។ លោកអ៊ំបានពន្យល់ថា ទាហ៊ានទាំងនោះ មានសុទ្ធតែប្រុសៗទាំងអស់ ។ ហើយកន្លែងសម្លាប់ទាំងអស់មានបីកន្លែង មួយកន្លែងៗមានប្រហែល៣០នាក់ ។ ចម្ងាយពីកន្លែងមួយទៅកន្លែងមួយ ឆ្ងាយពីគ្នាប្រហែល២០០ម៉ែត្រ ។ នៅមានប្រជាជនជាច្រើននាក់ទៀតដែលត្រូវយកមកសម្លាប់នៅទីនេះដែរ ។ តាមការ សន្និដ្ឋានរបស់លោកអ៊ំថា សរុបទាំងទាហាន ទាំងប្រជាជនគឺមានចំនួនប្រហែលជាង៣០០នាក់ ។ ហើយការ សម្លាប់នេះប្រព្រឹត្តទៅនៅឆ្នាំ១៩៧៦ និង ១៩៧៧ ដោយបណ្ដើរមកទាំងខ្សែៗកាត់តាមភូមិប្រជាជន ដូច ដែលលោកអ៊ំ ឡុច ប្រាប់ថាមានបណ្ដើរកាត់តាមក្រោយផ្ទះរបស់គាត់អញ្ចឹងដែរ ។ អ្នកបណ្ដើរប្រជាជនទាំង នោះ ត្រូវបានស្គាល់ច្បាស់ថាជា កងឈ្លបប្រចាំឃុំអូរ ។ លោកអ៊ំនិយាយការពិតថា «អ្នកដែលចាប់ប្រជាជនទាំងនោះមក គឺជាកងទ័ព ហើយក្រោយពីការចាប់បានហើយ ត្រូវប្រគល់ទៅឲ្យកងឈ្លបប្រចាំស្រុក និង ក្រោយបន្ទស់ត្រូវបញ្ជូនមកឲ្យឈ្លបឃុំជាអ្នកសម្លាប់» ។

**ទីតាំងសម្លាប់វាលចោលដាល** លេខកូដភូមិសាស្ត្រ: ០៥០៦០៩

ចោលដាល ជាវាលមួយដែលអ្នកស្រុក អ្នកភូមិនិយមហៅតាំងពីដើមរៀងមក ។ វាលនេះ បច្ចុប្បន្ន ជាវាលដែលគួរឲ្យភ័យខ្លាចមួយដែលស្ថិតនៅក្នុងព្រៃភ្នំដែលមានដើមឈើធំៗជាច្រើន ហើយជាពិសេសទៅទៀតស្ថិតនៅក្នុងទឹកដីដែលរដ្ឋអំណាចប្រគល់ទៅឲ្យពួកខ្មែរក្រហមផ្ដាច់ខ្លួនក្រោយពេលធ្វើសមាហរណកម្មរួច ។ នៅតាមដងផ្លូវក្រហេងក្រហូង និងលំបាក ក្រុមយើងតែងបានជួបប្រជាជនជាគ្រួសារតូចៗ រស់នៅឆ្ងាយៗ ដាច់ពីគ្នារវាងខ្ទមមួយទៅខ្ទមមួយ រួមជាមួយនឹងមុខរបរដែលមិនអាចអត់បានគឺ «ដុតធ្យូង» ។ មាន ឡ សម្រាប់ដុតធ្យូងជាច្រើនស្ថិតនៅក្នុងព្រៃ ។ ដើមឈើធំល្មមដុត ត្រូវបានកាប់ធ្វើធ្យូងដោយលួចលាក់ពីរដ្ឋ

អំណាច ។ ក្នុងចម្ងាយដីប្រហែល១៧គីឡូ ម៉ែត្រពីភូមិអ្នកស្រុក(ភូមិសំបូរ) យើងបានធ្វើដំណើរជាងពីរម៉ោង ទើបទៅដល់ទីតាំងវាលបោលជាល ។ ការកំណត់ទីតាំងតាមរយៈម៉ាស៊ីនកត់ត្រាតាមផ្កាយរណប បានត្រូវធ្វើឡើងជាបន្ទាន់ដែរគឺយើងកំណត់យកបាននូវចំណុចខ្សែស្របលេខ ១ណព ១១° ១៤' ២៩"២១ និងរយៈទទឹង១ដែ ១០៤° ១៩' ០៥"១៩ ។ ឯការសម្ភាសន៍រវាងក្រុមស្រាវជ្រាវយើងជាមួយលោកពូឃិន យ៉ាន ក៏បានធ្វើឡើងក្នុងពេល តែមួយ ។ លោកពូឃិន យ៉ាន អាយុ៤៦ឆ្នាំ សព្វថ្ងៃជាមេភូមិសំបួរ ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ បានបង្ហើបប្រាប់យើងថា វាលបោលជាលនេះមានសម្លាប់តែប្រពន្ធទាហាន កូនទាហាន ដែលយកមកពីខាងដោះកញ្ជរដែលមានចំនួនច្រើនជាង២០០នាក់ ។ វាលបោលជាល ស្ថិតនៅក្នុងភូមិដំបូករូង ឃុំដំបូករូង ។ ការសម្លាប់ប្រព្រឹត្តទៅនៅក្នុងខែ៥ ឆ្នាំ១៩៧៥ ដោយទុកបោលខ្មោចនៅកណ្តាលវាលប្រងើងប្រងាំងពេញព្រៃ ។ តាមការផ្តល់ពត៌មានពីលោកពូប្រធានភូមិសំបួរថា« ពេលយកប្រពន្ធកូនទាហានមកដល់ដំបូង គឺគេ(ខ្មែរក្រហម) ឲ្យអង្គុយសម្រាកត្រឹមត្រូវ បន្ទាប់គេចាប់ផ្តើមប្រជុំណែនាំថាឲ្យមករស់នៅលើដីនេះព្រោះមានស្រែធ្វើ មានអ៊ីៗ គ្រប់បែបយ៉ាង ។ លុះដល់អង្គការមក សុំឲ្យយើងទាំងអស់នាំគ្នាទះដៃអបអរសាទរអង្គការទៅ ។ មានឯណា! ដល់អង្គការគេមកដល់ អង្គការនោះបានបាញ់រះសម្លាប់អស់ទៅ» ។ នេះជាវិធីសម្លាប់មួយដែលគ្មាននរណាម្នាក់បានដឹងជាមុនឡើយ ។ កុំថាឡើយមនុស្សចាស់ សូម្បីតែក្មេងតូចៗក៏គ្មាននរណាម្នាក់រួចជីវិតពីការបាញ់រះនេះបានឡើយ ។

**ទីតាំងសម្លាប់ត្រពាំងស្តុកអិល** លេខកូដភូមិសាស្រ្ត: ០៥០៦១០

ត្រពាំងស្តុកអិល មានចម្ងាយប្រហែល៦គីឡូម៉ែត្រពីវាលបោលជាលទៅទិសខាងលិចឆៀងខាងជើង ស្ថិតនៅក្នុងទឹកដីភូមិក្រាំងតាសោ ឃុំដំបូករូង ដែលមានចំណុចខ្សែស្របលេខ១ណព ១១° ១២' ៣០"៩៥ និងរយៈ ទទឹង១ដែ ១០៤° ១៦' ២៣"៦៧ ។ ទីតាំងនេះមិនខុសគ្នាប៉ុន្មានពីទីតាំងសម្លាប់វាលបោលជាលឡើយ ព្រោះទាំងការ សម្លាប់ ទាំងការយកមនុស្សមកសម្លាប់គឺចេញមកពីប្រភពតែមួយ ។ លោកពូ យ៉ាន បានប្រាប់ថាអ្នកទោសសុទ្ធតែនារីជាប្រពន្ធ និងកូនចៅទាហាន ដែលយកមកពីដោះកញ្ជរ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ។ ហើយការ សម្លាប់ទៀតសោតក៏ដូចគ្នាដែរ ។ អ្នកទោសតម្រូវឲ្យឈរចាំទទួលអង្គការមកដល់ ហើយក៏ទទួលការបាញ់រះពី អង្គការស្លាប់គ្មានសល់ ។ ពាក្យថា “អង្គការ”ក្នុងន័យនេះគឺស្មើនឹងពាក្យ “គណៈឃុំ” ។ ជនរងគ្រោះដែលបាន ស្លាប់នៅត្រពាំងស្តុកអិល មានចំនួនច្រើនជាងនៅ វាលបោលជាល ព្រោះថាវាមានបរិវេណធំ ហើយស្ងាត់ បំផុត ។ សាកសពចំនួនប្រហែល ៥០០នាក់ ទាំងក្មេង ទាំងចាស់

បានត្រូវសម្លាប់យ៉ាងអណោចអធមនៅ ត្រពាំងស្តុកអិល ។ ទីតាំងសម្លាប់ត្រពាំងស្តុកអិល និងទីតាំងវាលចោលដាង ក្រោយពីការសម្លាប់នៅឆ្នាំ ១៩៧៥-៧៦មក ទីតាំងនេះមិនមានការសម្លាប់ទៀតទេ ។

៣) ស្រុកខត្តុង

ថ្ងៃទី២១-២២ ខែកក្កដា ឆ្នាំ២០០១

**មន្ទីរសន្តិសុខបឹងវ៉ា** **លេខកូដភូមិសាស្រ្តៈ០៥០៥០៣**

នៅឃុំត្រាចទងមានមន្ទីរសន្តិសុខមួយកន្លែងប្រចាំឃុំផ្ទាល់ ។ មន្ទីរសន្តិសុខនេះ មានឈ្មោះហៅថាមន្ទីរសន្តិសុខបឹងវ៉ា ឬ គុកបឹងវ៉ា ។ បើគិតតាមការកំណត់របស់ម៉ាស៊ីនកត់ត្រាភូមិសាស្រ្តតាមផ្កាយរណបទីតាំងនេះ មានចំណុចខ្សែស្របលេខ១ណាឌ ១១° ៤២' ៤៨"៦០ និងរយៈទទឹង១ដៃ ១០៤° ៣៥' ៤៩"៣៤ ។ មន្ទីរសន្តិសុខនេះ មានឃុំ ឃាំងប្រភេទអ្នកទោសស្រាលប៉ុណ្ណោះ ។ ឯអ្នកទោសធ្ងន់ត្រូវបានបញ្ជូនបន្តទៅកាន់មន្ទីរសន្តិសុខនៅភ្នំបាសិទ្ធ (ទីតាំងនេះក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅធ្វើការសិក្សារួចហើយ) ។ មន្ទីរឃុំឃាំង នេះស្ថិតនៅភូមិបឹងវ៉ា ឃុំត្រាចទង ។ នៅពេលដែលក្រុមស្រាវជ្រាវយើង បានទៅដល់ទីតាំងគុកនោះ យើងមិនបានឃើញអ្វីបន្តិចដែលជាសំណល់របស់មន្ទីរឃុំឃាំងនោះឡើយ
ក្រៅពីផ្ទះប្រជាជនដែលបានសង់នៅជាប់ៗគ្នា ។ ជ័យ ស៊ីម អាយុ៤៦ឆ្នាំ បច្ចុប្បន្នជាប្រជាជននៅភូមិបឹងវ៉ា ឃុំត្រាចទង ស្រុកខត្តុង ខេត្តកំពង់ស្ពឺ ហើយដែលបានសាងសង់ផ្ទះនៅលើដីនៃអតីតរោងឃុំឃាំងមនុស្សកាលពីជំនាន់ប៉ុលពត បាននិយាយរឿងរ៉ាវទាក់ទងនឹងគុកនេះប្រាប់ថា ក្រោយពីទទួលបានជ័យជំនះឆ្នាំ១៩៧៥មក ប្រជាជននៅក្នុងភូមិនេះត្រូវបានជម្លៀសចេញទៅនៅទៅនៅឃុំថ្មី ដោយមិនអនុញ្ញាតិឲ្យប្រជាជនរស់នៅក្នុងភូមិនេះសូម្បីតែម្នាក់ឡើយ ។ មូលហេតុនៃការជម្លៀសចេញ គឺកន្លែងនេះត្រូវជំនួសដោយមន្ទីរសន្តិសុខសំរាប់ឃុំត្រាចទងទៅវិញ ។ ទីតាំងសន្តិសុខនេះ បានបង្កើតឡើងនៅឆ្នាំ១៩៧៥ មកទល់ដើមឆ្នាំ១៩៧៩ ។ អ្នកទោសណាក៏ដោយឲ្យតែមានកំហុសបន្តិចបន្តួច គឺត្រូវបញ្ជូនមកកន្លែងនេះទាំងអស់ ។ កំហុសនោះ ត្រូវបានលោកជ័យ ស៊ីមលើកឡើងថា "អ្នកខ្លះគ្រាន់តែលួចដំឡូងស៊ី ក៏យកមកលត់ដំនៅមន្ទីរឃុំឃាំងបឹងវ៉ាដែរ ដើម្បីឲ្យធ្វើការគ្រប់ជំពូក ។ ទំរាំតែលែងឲ្យទៅវិញគឺពីពីរទៅបីខែឯណោះ" ។ មិនតែប៉ុណ្ណោះ លោកពូបន្ថែមថាឲ្យតែមានទំនាស់ជាមួយអង្គការ

ទាំងសំដី ទាំងការងារ ទាំងសតិអារម្មណ៍ ឬយើងមិនចេះកសាងខ្លួន ក៏ត្រូវបញ្ជូនខ្លួនមកដាក់នៅមន្ទីរឃុំឃាំងនេះដែរ ។ អ្នកទោសគ្រប់ប្រភេទ ឲ្យតែមានកំហុសគឺចាប់យកមកទាំងអស់ ។ ក្រោយបែកឆ្នាំ១៩៧៩ មន្ទីរនេះ បានបន្សល់ទុកនូវរោងចំនួន៤ ហើយរោងនិមួយៗមានបណ្តោយប្រហែល៦ម៉ែត្រ និងទទឹង៤ម៉ែត្រ ផ្ទុកអ្នកទោសតែចំនួនប្រហែល២០នាក់ប៉ុណ្ណោះ ។ អ្នកទោសត្រូវបញ្ជូនទៅកាប់ដីដីបូងដាក់ស្រែ និងដាំដំឡូង នៅឆ្ងាយពីមន្ទីរឃុំឃាំងនាពេលថ្ងៃ ។ ពេលល្ងាចបញ្ជូនចូលគុកវិញ ។ អ្នកទោសដែលកសាងខ្លួនបានល្អ ត្រូវបានដោះលែងវិញ ប៉ុន្តែប្រសិនបើអ្នកទោសណាដែលកសាងខ្លួនមិនបាន គឺត្រូវបញ្ជូនយកទៅសម្លាប់នៅក្នុងព្រៃខាងកើតភូមិបឹងវ៉ា ។ លោកពូបានសន្និដ្ឋានរួមថា អ្នកទោសដែលបានមកជាប់នៅមន្ទីរឃុំឃាំងបឹងវ៉ាទាំងអស់ សរុបទៅមានចំនួនប្រហែល៥០០នាក់ ។ នេះគាត់សរុបតាំងពីបង្កើតគុកដីបូងរហូតដល់បែកឆ្នាំ១៩៧៩ ។

សន្និដ្ឋានរួម

ក្នុងការចុះស្រាវជ្រាវលើស្រុកចំនួនបីខាងលើ ថ្វីត្បិតតែមិនចុះអស់ទីតាំងដែលក្រុមយើងបានគ្រោងទុកពិតមែន ប៉ុន្តែយ៉ាងហោចណាស់ក៏បានសម្រេចផែនការ៩០ភាគរយដែរ ។ ឯលទ្ធផលវិញ ឃើញថាល្អ ព្រោះថាកន្លែងដែលយើងទៅមិនដល់កាលពីពេលមិន(១៩៩៥-២០០០) ឥឡូវនេះគឺយើងបានទៅដល់ផ្ទាល់ជាក់ស្តែង មន្ទីរ៩៩ នៅស្រុកឱរ៉ាល់ជាដើម ។ ឯស្រុកពីរទៀត ក៏ដូចគ្នា យើងបានចុះទៅដល់ទីតាំងដែលយើងបានគ្រោងទុក ប៉ុន្តែក្នុងនោះនៅមានទីតាំងមួយចំនួនដែលនៅតែទៅមិនបាន ។ ហើយទីតាំងខ្លះដែលយើងបានសរសេរក្នុងគំរោង គឺមិនមែនជាទីតាំងទេ ព្រោះរបាយការណ៍មុនៗ បានសរសេរខុស ។ ចំពោះបញ្ហាសន្តិសុខវិញគឺ គ្មានអ្វីចោទជាបញ្ហាទេ ។ ទោះជាយ៉ាងនេះក៏ដោយ ក្រុមស្រាវជ្រាវយើងនៅតែប្រយ័ត្នខ្លួនជានិច្ចទាំងកាយវិការ ទាំងការនិយាយស្តី ជាពិសេសក្នុងការសម្ភាសន៍ ។ មានស្រុក២ ដែលយើងត្រូវប្រយ័ត្នប្រយែងបំផុត គឺស្រុកឱរ៉ាល់ និងស្រុកភ្នំស្រួច ព្រោះប្រជាជនភាគច្រើន សុទ្ធតែជាមនុស្សដែលមានការពាក់ពន្ធ័ជាមួយពួកខ្មែរក្រហមកាលពីមិនទាន់មានសមាហរណកម្មកើតឡើង ។ ចំណែកទីតាំងមួយចំនួនដែលមិនបានទៅដល់ ឬបានត្រឹមតែយកពត៌មាន គឺជាការជាក់ស្តែងមួយដែលមិនអាចទៅបាន ។ ខាងក្រោមនេះ ជាទីតាំងដែលក្រុមស្រាវជ្រាវយើងមិនបានទៅដល់ៈ

១) ស្រុកភ្នំស្រួចៈ

- ក្រាំងរមាស ជាទីតាំងសម្លាប់បន្ទាប់បន្សំ ស្ថិតក្នុងឃុំព្រៃក្មេង
- ក្រាំងសំរ៉ែ ជាទីតាំងសម្លាប់បន្ទាប់បន្សំ ស្ថិតក្នុងឃុំអូរ

២) ស្រុកខគ្គុង

- ព្រៃប្រម៉ាត់ដី ជាទីតាំងសម្លាប់និងមន្ទីរសន្តិសុខ ស្ថិតក្នុងឃុំត្រាចទង
- ស្តុកស្រាត ទីតាំងសន្តិសុខ ស្ថិតក្នុងឃុំមានជ័យ